EUROPEAN UNION

Cooperation Committee for Cambodia

Comité de Coopération Pour le Cambodge

Brot für die Welt

# ពិធីសម្ពោធការចាប់ផ្តើមអនុវត្តគម្រោង
# "ការពង្រឹងសង្គមស៊ីវិលដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
# និងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា"
# ដំណាក់កាលទី ២

កាលបរិច្ឆេទ៖ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២១

ទីកន្លែង៖ សណ្ឋាគារ (ជូនដំណឹងពេលក្រោយ) នៅភ្នំពេញ និង ការចូលរួមពីចម្ងាយ (អនឡាញ)

## ១. សេចក្តីសង្ខេបស្តីពីគម្រោង - ដំណាក់កាល ទី ១ និង ២

គម្រោង "**ការពង្រឹងសង្គមស៊ីវិលដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង ប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា" ដំណាក់កាលទី ២** ក្រោមការគាំទ្រមូលនិធិដោយសហភាពអឺរ៉ុប (E.U) និងអង្គការ Bread for the World (BfdW) និងត្រូវអនុវត្តដោយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ ស ក) ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៣ ។ គម្រោងក្នុងទំហំទឹកប្រាក់សរុប ៧៥០ ០០០ អឺរ៉ូ (ប្រាំពីរសែន ប្រាំម៉ឺន អឺរ៉ូ) នេះជាសមាសធាតុដ៏សំខាន់នៃកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច ដែលជាកម្មវិធីទោលប្រកបដោយវិសេសភាពរបស់អង្គការ គ.ស.ក ។

គម្រោងនេះមានកម្មវត្ថុជាក់លាក់ចំនួន ០៣ ដើម្បី ១. លើកកម្ពស់នូវបរិយាកាសអំណោយផល និងលំហប្រជាធិបតេយ្យ សម្រាប់អង្គការសង្គមស៊ីវិល ២. ពង្រឹងអំណាចរបស់អង្គការសង្គមស៊ីវិល តាមរយៈការអភិវឌ្ឍសមត្ថភាព ភាពធន់រឹងមាំ និងភាពជាតំណាង និង ៣. បង្កើតមជ្ឈមណ្ឌលធនធានសម្រាប់អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ ។

ក្នុងដំណាក់កាលទី១ នៃការអនុវត្ត គម្រោង "**ការពង្រឹងសង្គមស៊ីវិលដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និង ប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា**" មានរយៈពេល ៤៥ ខែ ចាប់ផ្តើមពីខែ មេសា ឆ្នាំ ២០១៧ ដល់ ខែ ធ្នូ ឆ្នាំ ២០២០ មានសមិទ្ធិផលគួរឱ្យកត់សម្គាល់ដូចតទៅ ៖

- បានបញ្ចប់រួចរាល់នូវទម្រង់ថ្មីប្រព័ន្ធវិញ្ញាបនប័ត្រ ជី ភី ភី (បទដ្ឋានអភិបាលកិច្ចល្អ និងការអនុវត្តប្រកបដោយវិជ្ជាជីវៈ) ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។
- បានត្រួតពិនិត្យឡើងវិញ និងសម្រួចបទអន្តរាគមន៍ស្តីពីការអភិវឌ្ឍន៍សមត្ថភាពរបស់អង្គការ គ.ស.ក ដើម្បីឱ្យមានភាពបទបែនងាយស្រួល និងឆ្លើយតបប្រកបដោយប្រសិទ្ធិភាពស្របតាមតម្រូវការរបស់ អ្នកទទួលផល
- ពង្រីកវិសាលភាពនៃការគាំទ្រស្តីពីអភិបាលកិច្ចល្អ និងនិរន្តរភាពសម្រាប់អង្គការសហគមន៍មូលដ្ឋាន (អ ស ម)
- បានផលិតឯកសារសិក្សាស្រាវជ្រាវជាច្រើន ដែលពាក់ព័ន្ធជាមួយប្រតិបត្តិការ និងបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុង ប្រទេសកម្ពុជា
- សំណើ និងសំណូមពររបស់ អង្គការ គ ស ក ប្រមាណជា ៧០% ដែលបានលើកនៅក្នុងវេទិកានៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលត្រូវបានឆ្លើយតបដោយពេញលេញ និងដោយផ្អែកដោយរាជរដ្ឋាភិបាល

ដែលក្នុងនោះរួមមាននីតិវិធីនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការធ្វើអនុលោមភាពនៃច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងច្បាប់ស្តីពីការងារ និងភាពជាដៃគូ

- ការលើកកម្ពស់ការយល់ដឹង អភិវឌ្ឍន៍សមត្ថភាព និងការត្រួតពិនិត្យនិងវាយតម្លៃ (M&E) នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា មានភាពល្អប្រសើរឡើងនៅក្នុងចំណោមអង្គការសង្គមស៊ីវិល យុវជន និងសាធារណៈជន ។ កម្មវិធីយុវទូតស្ម័គ្រចិត្តដើម្បីគោលដៅអភិវឌ្ឍប្រកបដោយចីរភាព បានផ្តួចផ្តើមគំនិតថ្មីៗជាច្រើន ដោយលើកកម្ពស់នូវស្មារតីនៃការចូលរួមប្រកបដោយបរិយាប័ន្ននៅក្នុងចំណោមយុវជន នៅក្នុងរបៀបវារៈការងារគោលដៅអភិវឌ្ឍប្រកបដោយចីរភាព
- ពង្រឹងនូវភាពជាតំណាង និងការអភិវឌ្ឍសមត្ថភាពរបស់បណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្តដើម្បីនាំយកនូវសំណើរ និងសំណូមពរជូនដល់រដ្ឋាភិបាល ជាពិសេសតាមរយៈវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងកិច្ចសហប្រតិបត្តិការនានា
- មូលនិធិសង្គមស៊ីវិល (ម ស ស) ត្រូវបានបង្កើតឡើង និងបានក្លាយជារបៀបវារៈប្រកបដោយប្រសិទ្ធិភាពដើម្បីលើកកម្ពស់ការយល់ដឹងពីបម្រែបម្រួលមូលនិធិដល់អង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាននៅកម្ពុជា និងជួយសម្របសម្រួលឲ្យពួកគេមានលទ្ធភាពទទួលបានមូលនិធិ សម្រាប់បន្ត និរន្តរភាព របស់ខ្លួន។ រហូតមកដល់ពេលនេះ ម.ស.ស បានផ្តល់ជំនួយបន្តខ្នាតតូចចំនួន០៩ គម្រោង (០១ គម្រោងមានទឹកប្រាក់ ១៥,០០០អឺរ៉ូ) ដើម្បីគាំទ្រគំនិតផ្តួចផ្តើមល្អៗដែលអាចជំរុញឲ្យពួកគេអាចកៀរគរចំណូលសម្រាប់លើកកម្ពស់និរន្តរភាពរបស់ខ្លួន និងក្រុមអ្នកទទួលផល ។

## ២. ពិធីសម្ពោធការចាប់ផ្តើមអនុវត្តគម្រោង

អង្គការ គ.ស.ក នឹងរៀបចំពិធីសម្ពោធនៃការចាប់ផ្តើមអនុវត្តគម្រោង។ **ពិធីនេះនឹងត្រូវប្រារព្ធធ្វើនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១** ជាទម្រង់រួមគ្នានៃការជួបគ្នាដោយផ្ទាល់ និងពីចម្ងាយ នៅសណ្ឋាគារ (ភ្នំពេញ) ។ ពិធីនេះធ្វើឡើងដោយមានកម្មវត្ថុសំខាន់ៗចំនួន ០៤៖

- ស្វាគមន៍ជាផ្លូវការនូវដៃគូ និងភាគីពាក់ព័ន្ធនៅក្នុងគម្រោងនេះ
- រួមគ្នាកំណត់បញ្ហាអាទិភាព និងសកម្មភាពរួមដើម្បីអនុវត្តន៍គម្រោងក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ ១៩
- អបអរសាទរនូវសមិទ្ធិផលនៃគម្រោងក្នុងដំណាក់កាលទី១ និងដកស្រង់បទពិសោធន៍ល្អស្តីពីនិរន្តរភាពការងារសម្រាប់ គម្រោងដំណាក់កាលទី២
- ថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធដើម្បីលើកកម្ពស់នូវស្មារតីនៃកិច្ចសហប្រតិបត្តិការ និង ការគាំទ្រនានាដើម្បីធ្វើឱ្យសម្រេចនូវលទ្ធផល ។

ជាការគ្រោងទុក ពិធីសម្ពោធការចាប់ផ្តើមអនុវត្តគម្រោងនេះនឹងមានអ្នកចូលរួមប្រមាណ ១០០ នាក់ពីអន្តរវិស័យ និងស្ថាប័នពាក់ព័ន្ធនានាទាំងដោយផ្ទាល់ និងពីចម្ងាយ ។ អ្នកចូលរួមមានវត្តមានតំណាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត និងអ្នកសារព័ត៌មាន ។

### ៣. របៀបវារៈនៃកម្មវិធី

| ម៉ោង | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| 08:30-09:00 | ការចុះឈ្មោះចូលរួម និងការអញ្ជើញចូលរួម នៃគណៈអធិបតី | ក្រុមការងារនៃអង្គការ គ.ស.ក |
| **១. ពិធីសម្ពោធការចាប់ផ្តើមអនុវត្តគម្រោង** | | |
| 09:00-09:10 | គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>ការណែនាំពីកម្មវិធី និងរបៀបវារៈសំខាន់ៗ | ពិធីការិនី អ្នកស្រី **ផេង ច័ន្ទឌី** |
| 09:10-09:20 | មតិស្វាគមន៍ | អ្នកស្រី **ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិនៃអង្គការ គ ស ក |
| 09:20-09:30 | មតិគន្លឹះ | លោក Bryan FORNARI<br>ប្រធានសហប្រតិបត្តិការនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា |
| 09:30-09:50 | សុន្ទរកថាបើកកម្មវិធី | ឯកឧត្តម **ខ៉ាន់ ចំរើន**<br>រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ<br>និងជាប្រធានលេខាធិការដ្ឋាន គ ជ អ ប |
| 09:50-10:10 | **បទបង្ហាញស្តីពី៖**<br>- សមិទ្ធិផលនៃគម្រោងដំណាក់កាលទី ១<br>- គម្រោងដំណាក់កាលទី ២: លទ្ធផលរំពឹងទុក និង វិធីសាស្ត្រដើម្បីធ្វើឱ្យសម្រេចការងារ<br>**វេទិកា សំនួរ និងចម្លើយ** | អ្នកស្រី **លុយ ឆារី**<br>ប្រធានកម្មវិធី |
| 10:10:10:30 | ការថតរូបជុំគ្នា និងការប្រាស្រ័យទំនាក់ទំនងជាមួយនឹងអ្នកសារព័ត៌មាន | ទាំងអស់គ្នា |

***<u>កំណត់សម្គាល់:</u>*** *អ្នករៀបចំកម្មវិធី សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែ របៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។*